# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីពាក្យថាបាបនិងពាក្យថាបុណ្យ

**Website: www.hoksavann.org**

ថ្ងៃទី២៨ វិច្ឆិកា ២០០៤

### ១- អំពីពាក្យថាបាបនិងពាក្យថាបុណ្យ ៖

ពាក្យថា«បាប»ប្រើជាភាសាខ្មែរ ដែលចេញពីភាសាបាលីថា «បាបំ» ប្រែថាអំពើអាក្រក់ ។ ឯពាក្យថា«បុណ្យ»ក៏ប្រើជាភាសាខ្មែរ ដែលមានដើមកំណើតពីភាសាសំស្ក្រឹត ស្មើគ្នានឹងពាក្យបាលីថា «បុញ្ញំ» ប្រែថា ការជ្រះថ្លារីករាយចិត្ត ឬពេញចិត្តជាផ្នែកកុសល ។បុណ្យបាបនេះជាចេតនាអាក្រក់ល្អផ្លូវចិត្ត ទើបបញ្ចេញឲ្យប្រព្រឹត្តអាក្រក់ល្អតាមផ្លូវកាយនិងវាចា ។ ការជំរះសន្តានចិត្តឲ្យបានស្អាតបានល្អហៅថាបុណ្យ ។ ចិត្តសៅហ្មងហៅថាបាប ។ ចិត្តសៅហ្មងនាំឲ្យប្រព្រឹត្តអំពើអាក្រក់ ចិត្តបរិសុទ្ធនាំឲ្យប្រព្រឹត្តអំពើល្អ ។ បាបឲ្យផលជាទុក្ខ បុណ្យឲ្យផលជាសុខ ។ នេះជាអត្ថន័យខ្លះនៃពាក្យថាបាបនិងពាក្យថាបុណ្យ ។ ពាក្យថាបាប មានពាក្យប្រើផ្លាស់ប្តូរគ្នាបាន គឺអកុសល, ទុច្ចរិត, អយុត្តិធម៌, ធម៌ខ្មៅ (កាឡធម៌) ។ ឯពាក្យថាបុណ្យ ក៏មានពាក្យប្រើផ្លាស់ប្តូរគ្នាបាន គឺកុសល, សុចរិត, យុត្តិធម៌, ធម៌ស (សុក្កធម៌) ។

បាបនិងបុណ្យនេះ កើតចេញមកពីកាយវាចានិងចិត្តប្រចាំថ្ងៃរបស់មនុស្សក្នុងសង្គម បានដល់កុសលកម្មបថ១០ និងអកុសលកម្មបថ១០។ កុសលកម្មបថ១០ បានដល់កាយកម្ម៣ គឺវៀរចាកការសម្លាប់, ការលួច, ការប្រព្រឹត្តខុសក្នុងកាម គឺវៀរចាកការលួចប្រពន្ធកូនប្តីអ្នកដទៃ ។ វចីកម្ម៤ គឺវៀរចាកនិយាយកុហក, និយាយពាក្យញុះញង់, ពាក្យគំរោះគំរើយ និងពាក្យឥតប្រយោជន៍ ។ មនោកម្ម៣ គឺវៀរចាកគំនិតព្យាបាទ, គំនិតរំពៃចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ និងមានសម្មាទិដ្ឋិ ការយល់ត្រូវទៅតាមសភាពពិត។ ឯអកុសលកម្មបថ១០ មានលក្ខណៈផ្ទុយពីនេះ គឺពុំវៀរចាកអំពើអាក្រក់ដោយកាយ៣ ដោយវាចា៤ និងដោយចិត្ត៣នេះឯង ។ សកម្មភាពរបស់មនុស្សតែងតែប្រព្រឹត្តទៅតាមដំណើរកុសលកម្មបថ១០និងអកុសលកម្មបថ១០នេះ ដែលឲ្យឈ្មោះថាបុណ្យនិងបាប ។

### ២- ឧទាហរណ៍ខ្លះអំពីបុណ្យនិងបាប ៖

អំពីបុណ្យបាបនេះ បើនិយាយដោយបរិយាយសេចក្តី ដូចជាសិស្សនិងនិស្សិតខំសិក្សារៀនសូត្រ គោរពច្បាប់សាលា មានចរិយាល្អ នេះហើយជាបុណ្យ ព្រោះសកម្មភាពល្អនេះនាំឲ្យចំរើនលូតលាស់ខាងការសិក្សា ។ ផ្ទុយទៅវិញ បើសិស្សនិងនិស្សិតពុំយកចិត្តទុកដាក់ក្នុងការសិក្សា ពុំគោរពច្បាប់សាលា មានទៅរៀនយឺតពេល ពុំធ្វើកិច្ចការតាមមេរៀនដែលគ្រូដាក់ឲ្យ ដើរលេងប្រព្រឹត្តអបាយមុខផ្សេងៗជាដើម នេះជាបាប ព្រោះសកម្មភាពនេះនាំឲ្យខូចការសិក្សា ។ ម្តាយឪពុកកូនចៅប្តីប្រពន្ធបើចេះគោរពគ្នាតាមមុខងារ តាមតួនាទីរៀងខ្លួន មិនរំលោភលើគ្នា នេះជាបុណ្យដែលជាហេតុនាំឲ្យបានសេចក្តីសុខចំរើនក្នុងសង្គមគ្រួសារ ។ បើមានការរំលោភលើគ្នា ឈ្មោះថាបាប ដែលជាហេតុនាំឲ្យមានការទាស់ទែងខ្វែងគំនិតគ្នាក្នុងសង្គមគ្រួសារ ពុំបានសេចក្តីសុខឡើយ ។ ក្រុមហ៊ុនរោងចក្រនានា បើគោរពច្បាប់មានគោរពសិទ្ធិកម្មករជាដើម នេះជាបុណ្យ បើគេពុំគោរព មានការរំលោភសិទ្ធិកម្មករ ការកេងប្រវ័ញ្ចលើកម្លាំងកម្មករជាដើម នេះជាអំពើបាប ហើយអំពើនេះអាចមានកូដកម្មឬបាតុកម្មរបស់កម្មករប្រឆាំងនឹងការរំលោភនេះ បើដំណោះស្រាយដោយសន្តិវិធីពុំបានទទួលលទ្ធផលល្អតាមបំណងរបស់កម្មករទេ ។ សង្គមប្រទេសទាំងមូល បើរដ្ឋាភិបាល សភាជាតិ តុលាការ និងអាជ្ញាធរគ្រប់ក្រសួងបានបំពេញកិច្ចក្នុងក្នុងក្រសួងតាមមុខងាររបស់ខ្លួនឲ្យបានត្រឹមត្រូវ ក្នុងក្របខណ្ឌច្បាប់របស់រដ្ឋដើម្បីបំរើប្រជាពលរដ្ឋ នេះហើយជាអំពើល្អដែលហៅថាបុណ្យ ។ បើប្រព្រឹត្តផ្ទុយពីនេះ ឈ្មោះថាអំពើបាប ព្រោះបានសាងអំពើអាក្រក់នាំឲ្យខូចប្រយោជន៍ក្រសួងនិងប្រយោជន៍ជាតិទាំងមូល ។ បើអ្នកកាន់អំណាចជួយប្រទេសកម្ពុជាឲ្យចំរើនលូតលាស់ខាងសេដ្ឋកិច្ច ខាងវប្បធម៌ ជួយឲ្យមានការគោរពសិទ្ធិមនុស្ស នេះជាបុណ្យ ។ ផ្ទុយទៅវិញ បើអ្នកកាន់អំណាចគិតតែប្រយោជន៍ខ្លួន បក្សពួកខ្លួន ប្រព្រឹត្តអំពើពុករលួយ ធ្វើឲ្យប្រជាពលរដ្ឋរងទុក្ខវេទនាក្រីក្រលំបាក ព្រមទាំងប្រព្រឹត្តអំពើផ្តាច់ការ បំបិទសិទ្ធិគ្រប់យ៉ាងរបស់ប្រជាពលរដ្ឋ នេះជាអំពើបាប ហើយផលបាបនឹងផ្តល់ឲ្យអ្នកប្រព្រឹត្តវិញពុំខានឡើយ ។៚